**សេចក្តីប្រកាសព័ត៌មាន**

East Asia and Pacific Region
THE WORLD BANK

# របាយការណ៍បច្ចុប្បន្នភាពអាស៊ីបូព៌ា និងប៉ាស៊ីហ្វិក របស់ធនាគារពិភពលោកបានឱ្យដឹងថាៈ តម្រូវការក្នុងស្រុករបស់ប្រទេសចិនជួយជំរុញឱ្យសេដ្ឋកិច្ចតំបន់ងើបឡើងជាថ្មី ប៉ុន្តែប្រទេសមួយចំនួន នៅតែបន្តការប្រឈមនេះ

**ទីក្រុងវ៉ាស៊ីនតោន ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៩ —** ការងើបឡើងវិញនៃសេដ្ឋកិច្ចក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក មានសន្ទុះយ៉ាងលឿនដ៏គួឱ្យភ្ញាក់ផ្អើល និងគួឱ្យសាទរ ប៉ុន្តែបើដកប្រទេសចិនចេញពីការគណនានេះ ទិដ្ឋភាពទូទៅរបស់តំបន់នេះនៅមិនទាន់ប្រសើទេ នេះបើតាមការវាយតំលៃសេដ្ឋកិច្ចតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិករយៈពេល៦ខែរបស់ធនាគារពិភពលោក ។

របាយការណ៏បច្ចុប្បន្នភាពអាស៊ីបូព៌ា និងប៉ាស៊ីហ្វិកចុងក្រោយបំផុត ដែលមានចំណងជើងថា ***ការផ្ទេរការងើបឡើងឱ្យមកដូចដើមវិញនៃសេដ្ឋកិច្ច*** គឺដោយសារការចំណាយដ៏ធំធេងនិងទាន់ពេលវេលានៃកញ្ចប់ថវិកាជួយសង្គ្រោះសេដ្ឋកិច្ចនៅប្រទេសមួយចំនួនក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ដោយនាំមុខគេដោយប្រទេសចិន និងប្រទេសកូរ៉េ ព្រមទាំងដំណើរការ ដ៏មានឥទ្ធិពលមួយនៃការធ្វើសារពើភ័ណ្ឌស្តុកដែលកំពុងតែដំណើរការ បាននាំឱ្យមានការលោតឡើងវិញនៅក្នុងតំបន់ និងបានចូលរួមចំណែកយ៉ាងច្រើនចំពោះភាពនឹងន៎ដែលអាចធ្វើឱ្យពិភពលោកទទួលបានពីឥទ្ធិពលនេះផងដែរ ។

របាយការណ៏នេះបានឱ្យដឹងថា ការអភិវឌ្ឍនៅក្នុងតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិកនៅតែទទួលឥទ្ធិពលយ៉ាងខ្លាំងពីប្រទេសចិន ដែលគេបានទស្សទាយថាកំណើន GDP សម្រាប់ឆ្នាំ ២០០៩ នឹងទូទាត់៣/៤នៃការធ្លាក់ចុះ GDP របស់សហរដ្ឋអាមេរិក ប្រទេសក្នុងតំបន់អឺរ៉ុប និង ប្រទេសជប៉ុន។ បើទោះបីជាប្រទេសឥណ្ឌូនេស៊ី និងប្រទេសវៀតណាម មានកំណើនប្រសើរក្តី ក៏ប្រទេសកំពុងអភិវឌ្ឍន៏នៅអាស៊ីបូព៌ា ដោយមិនរាប់បញ្ចូលប្រទេសចិន គឺត្រូវបានគេទស្សទាយថានឹងមាន កំណើនកើនឡើងតែ ១ ភាគរយ ប៉ុណ្ណោះនាឆ្នាំ ២០០៩ នេះ គឺកើនឡើងយឺតជាងតំបន់អាស៊ីខាងត្បូង មជ្ឈឹមបូព៌ា និងអាហ្វ្រិកខាងត្បូង ហើយវាមានភាពប្រសើរតែបន្តិចបន្តួចជាងអនុតំបន់អាហ្វ្រិកសាហារា ។ ប្រទេសមួយចំនួននៅតែបន្តការប៉ះពាល់យ៉ាងធំដដែល ហើយ GDP របស់គេ គឺមានតួលេខកំណើនជាអវិជ្ជមាន ដូចជាប្រទេសកម្ពុជា ម៉ាឡេស៊ី ថៃ និងមានការកើនឡើងតែបន្តិចបន្តួច ប៉ុណ្ណោះសម្រាប់ប្រទេស ម៉ុហ្គោលី និងប្រទេសមួយចំនួននៅកោះនៃសមុទ្រប៉ាស៊ីហ្វិក។

ដោយសហគ្រាស (ទាំងផ្លូវការនិងមិនផ្លូវការ) បានកាត់តម្រូវកម្លាំងពលកម្មដែលមានភាពទន់ខ្សោយកាលពីដើមឆ្នាំ កម្មករនៅទូទាំងតំបន់បានទទួលរងផលប៉ះពាល់ដោយមធ្យោបាយផ្សេងៗគ្នា។ សហគ្រាស បានកាត់បន្ថយម៉ោងធ្វើការរបស់កម្មករ លុបបំបាត់ការធ្វើការប្តូរវេនបន្ថែម បញ្ឈប់កម្មករបណ្តោះអាសន្ន ឬកម្មករមានកិច្ចសន្យា ឬបញ្ចុះកម្រៃប្រាក់ឈ្នួល ប៉ុន្តែវិធាន

ទាំងនេះ ពេលនេះត្រូវបានដើរបញ្ច្រាសវិញ ។ ពិតណាស់មានបុគ្គលិកពេញម៉ោងមួយចំនួនតូចត្រូវបានបញ្ឈប់ ដោយសារតែក្រុមហ៊ុនបានព្យាយាមកំហិតចំនួននៃការជ្រើសរើសបុគ្គលិក និងតម្លៃនៃការបណ្តុះបណ្តាលនៅពេលដែលតម្រូវការកើនឡើងវិញ ។ កម្មករដែលបានបញ្ឈប់កាលពីពេលមុន ពួកគេបានរកការងារបានធ្វើនៅក្នុងផ្នែកសេវាកម្ម និងកសិកម្ម ជាពិសេសនៅក្នុងវិស័យមិនផ្លូវការ ហើយមានប្រាក់ឈ្នួលទាប និងមានការប្រឈមនឹងលក្ខខណ្ឌការងារ ។ នៅក្នុងប្រទេសមួយចំនួនកញ្ចប់ថវិកាជួយសង្គ្រោះសារពើពន្ធបានគាំទ្រដល់ការបង្កើតការងារសាធារណៈបណ្តោះអាសន្ន។

របាយការណ៍បានប៉ាន់ប្រមាណថា ប្រជាជន ១៤ លាននាក់ អាចនឹងបានងើបចេញពីភាពក្រីក្រដែលមានចំណូល ២ ដុល្លាក្នុងមួយថ្ងៃ ប្រសិនបើសេដ្ឋកិច្ចនៅមានកំណើនដូចមុនពេលមានវិបត្តិនោះ ពេលនេះពួកគេនៅក្នុងភាពក្រីក្រដដែលនៅក្នុងឆ្នាំ ២០១០។

ទោះជាយ៉ាងណាក៏ដោយ ជាមួយនឹងការទស្សទាយកំណើន កើនឡើង ៨,៤ ភាគរយ នៅក្នុងប្រទេសចិនក្នុងឆ្នាំនេះ ហើយតម្រូវការក្នុងស្រុករបស់ប្រទេសនេះបាននាំមុខគេនូវតម្រូវការពិភពលោក ប្រទេសដែលនាំចេញទំនិញប្រើប្រាស់ ទំនិញផ្នែកអេឡិចត្រូនិច និងវត្ថុធាតុដើមទៅប្រទេសចិន បានទទួលភាពវិជ្ជមានចំពោះសេដ្ឋកិច្ចរបស់ខ្លួន។ ជាលទ្ធផល ធនាគារពិភពលោក កំពុងតែទស្សទាយកំណើនសេដ្ឋកិច្ចថា នឹងមាន ៦,៧ ភាគរយនៅឆ្នាំ ២០០៩ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក ហើយនឹងមានប្រមាណ ៧,៨ ភាគរយនៅឆ្នាំខាងមុខ។ ដូចដែលមន្ត្រី រដ្ឋមន្ត្រី និងប្រមុខរដ្ឋមកពីប្រទេស ២១ ដែលជាសមាជិកវេទិកាសហប្រតិបត្តិការសេដ្ឋកិច្ចអាស៊ី-ប៉ាស៊ីហ្វិក នឹងនាំប្រតិភូទៅចូលរួមប្រជុំនៅប្រទេសសឹង្ហបូរីនៅចុងសប្តាហ៍នេះ ប្រធានសេដ្ឋកិច្ចវិទូរបស់ធនាគារពិភពលោកប្រចាំតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិក លោក វីក្រាម នេរុ បានក្រើនរំលឹកថា ហានិភ័យសម្រាប់ការងើបឡើងវិញប្រកបដោយចីរភាពនៅតែមាននៅឡើយ។

លោក នេរុ មានប្រសាសន៍ថា "រដ្ឋាភិបាលខ្លះនៅក្នុងតំបន់នឹងមានពេលសម្រាប់ធ្វើឱ្យមានចីរភាពចំពោះថវិកាជួយសង្គ្រោះសារពើពន្ធរហូតទាល់តែសេដ្ឋកិច្ចវិលទៅរកភាពដើមវិញប្រកបដោយភាពរឹងមាំ"។ លោកបានបន្ថែមថា "ពេលវេលាសម្រាប់ការចាប់ផ្តើមដកចេញនៃការជួយជ្រោមជ្រែងរូបិយប័ណ្ណនឹងអាចធ្វើលឿនជាងនេះ ប៉ុន្តែដោយមានការព្រួយបារម្ភ ជាពិសេសលើតម្លៃមិននឹងន់នៃទ្រព្យសកម្ម"។

លោកមានប្រសាសន៍ថា ដោយសម្លឹងមើលទៅឆ្ងាយពីឆ្នាំ ២០០៩ ប្រទេសមួយចំនួននៅក្នុងតំបន់នេះអាចមានកំណើនឆាប់រហ័ស បើទោះបីជាកំណើននៅក្នុងសេដ្ឋកិច្ចដែលអាចប្រកួតប្រជែងបានមានភាពយឺតយ៉ាវក្តី។ ដើម្បីទាញយកឱកាសសក្តានុពលពីកំណើននៅខាងមុខនេះ ប្រទេសទាំងនោះត្រូវតែតទល់នឹងការឧបត្ថម្ភនិយម (គោលនយោបាយការពារសេដ្ឋកិច្ច

ពីការប្រកួតប្រជែងពីប្រទេសផ្សេងៗ) បន្តការបើកទូលាយ និងបើកចំហបន្ថែមទៀត ដោយមិនកាត់បន្ថយការធ្វើសមាហរណកម្មសេដ្ឋកិច្ចនៅក្នុងតំបន់នឹងនៅក្នុងពិភពលោក។

លោក នេរុ មានប្រសាសន៍ថា "ការបង្កើនខ្សែសង្វាក់តម្លៃបន្ថែមចំពោះបណ្តាញផលិតកម្មក្នុងពិភពលោក និងក្នុងតំបន់ គួរត្រូវដឹកនាំទៅរកភាពលូតលាស់នៃផលិតភាព និងកំណើនយ៉ាងរឹងមាំ ហើយអនុញ្ញាតឱ្យបច្ចេកវិទ្យាថ្មី និងការច្នៃប្រឌិតថ្មីៗរីកសាយភាយឱ្យបានទូលំទូលាយតាមរយៈសេដ្ឋកិច្ចតំបន់" ។

អ្នកតាក់តែងរបាយការណ៍នេះ គឺលោក អ៊ីវ៉ាឡូ អ៊ីសូស្តី មានប្រសាសន៍ថា វិបត្តិបានជួយរដ្ឋាភិបាលឱ្យទទួលស្គាល់ថា កំណើនបន្ថែមអាចទាញយកបានពីតម្រូវការក្នុងស្រុក ប្រសិនបើការដាក់កំហិតចំពោះការពង្រីកនៅក្នុងការប្រើប្រាស់ពីវិស័យឯកជន និងសេវាកម្មត្រូវបានដោះស្រាយ។

លោក អ៊ីសូស្តីមានប្រសាសន៍ថា "ការធ្វើឱ្យមានសមតុលឡើងវិញលើកំណើន វាមិនតម្រូវឱ្យយើងគិតថា វាជាជម្រើសមួយរវាងការផ្តេកផ្តួលទៅលើទីផ្សារពិភពលោក ឬលើទីផ្សារក្នុងស្រុកនោះទេ។ វាអាចជាអ្វីដែលយើងអាចទាញយកពីកំណើនថែមទៀតពីតម្រូវការក្នុងស្រុក ដែលវាជាការចូលរួមបន្ថែមទៅនឹងការកើនឡើងនៃសមាហរណកម្មជាមួយសេដ្ឋកិច្ចតំបន់ និងសេដ្ឋកិច្ចពិភពលោក ។ ការសម្របសម្រួលការអភិវឌ្ឍវិស័យសេវាកម្ម ការដោះស្រាយបញ្ហាហេដ្ឋារចនាសម្ព័ន្ធ និងការជំរុញគុណភាពការអប់រំ ត្រូវតែធ្វើឡើងដោយការអភិវឌ្ឍកំណត់គោលដៅឱ្យបានប្រសើរ និងផ្តល់ថវិកាដល់ប្រព័ន្ធគាំពារសង្គម។

លោក អ៊ីសូស្តី មានប្រសាសន៍ថា "ទាំងការអប់រំ និងសុខភាព ការលើកកំពស់ប្រព័ន្ធគាំពារសង្គម នឹងជួយកាត់បន្ថយការសន្សំសំចៃដែលអាចការពារបាន លើកកំពស់កម្លាំងស្និតរមួតក្នុងស្រុកក្នុងអំឡុងពេលដែលមានសមាហរណកម្មយ៉ាងលឿននៅក្នុងតំបន់ និងពិភពលោក ហើយអាចធ្វើឱ្យប្រទេសទទួលបានផលប្រយោជន៍ពីសេដ្ឋកិច្ចដ៏ធំធេងនេះ ទាំងនោះជាគន្លឹះសម្រាប់ការទទួលបានជោគជ័យលើសេដ្ឋកិច្ចរយៈពេលវែង" ។

---

របាយការណ៍បច្ចុប្បន្នភាពអាស៊ីបូពា៌ និងប៉ាស៊ីហ្វិក គឺជាការពិនិត្យមើលឡើងវិញយ៉ាងទូលំទូលាយរបស់ធនាគារពិភពលោកអំពីសេដ្ឋកិច្ចនៅក្នុងតំបន់ ។ របាយការណ៍នេះ គឺបោះពុម្ពពីរដងក្នុងមួយឆ្នាំ ហើយអាចរកវាបានដោយឥតគិតថ្លៃតាមរយៈវេបសាយនេះ http://www.worldbank.org/eapupdate បន្ទាប់ពីការបម្រាមត្រូវបានលើកចេញ។

របាយការណ៍ទាំងមូលដែលមានភ្ជាប់ជាមួយការដាក់បម្រាម គឺអាចរកបានសម្រាប់អ្នកសារព័ត៌មានដែលបានចុះឈ្មោះនៅក្នុងមជ្ឈមណ្ឌលអេឡិចត្រូនិចសម្រាប់សារព័ត៌មាន ។ អ្នកសារព័ត៌មានដែលបានចុះឈ្មោះហើយនឹងទទួលបានការជូនដំណឹងជាស្វ័យប្រវត្តិ។ សម្រាប់ចុះឈ្មោះសូមចូលទៅវេបសាយនេះ៖ http://media.worldbank.org/

ទំនាក់ទំនង:


នៅភ្នំពេញ
លោក ប៊ូ សារឿន (៨៥៥ ២៣) ២១៧ ៣០១
sbou@worldbank.org

នៅទីក្រុងវ៉ាស៊ីនតោន
លោកស្រី អេលីសាបែត មៀលី +1 (202) 458-4475
emealey@worldbank.org
លោក ម៉ូហាមេត អាល អារីហ្វ +1 (202) 352-4745
malarief@worldbank.org